(នេះជាលិខិតបកប្រែពីភាសាអង់គ្លេសដែលបានដាក់ជូនឯកអគ្គរដ្ឋទូតកាលពីថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣)

លិខិតចំហ

គោរពជូនឯកឧត្តម យ៉ាសេច ឡាវ ឯកអគ្គរដ្ឋទូត សាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវប្រចាំនៅកម្ពុជា

ទាក់ទិនទៅនឹងការបាត់ខ្លួនសកម្មជនការពារសិទ្ធិមនុស្ស

ឥលោក សម្បត្តិ សំភូន

ឯកឧត្តមជាទីគោរព មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(ម.ស.ម.ក)សូមសម្តែងនូវក្តីព្រួយបារម្ភយ៉ាងជ្រាលជ្រៅទាក់ទិនទៅនឹងការបាត់ខ្លួននៃសកម្មជនការពារសិទ្ធិមនុស្សដ៏លេចធ្លោគឺលោក សម្បត្តិ សំភូន (Sombath Samphone)នៅទីក្រុងវៀងចាន់កាលពីថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១២។ លោកសម្បត្តិ សំភូនត្រូវបានគេទទួលស្គាល់ចំពោះការងារអប់រំ និងការបណ្តុះបណ្តាលយុវជនដើម្បីលើកស្ទួយការអភិវឌ្ឍន៍ជានិរន្តរភាពក្នុងប្រទេសឡាវ។ លោកគឺជាស្ថានិកនៃមជ្ឈមណ្ឌល*ចូលរួម អភិវឌ្ឍន៍ បណ្តុះបណ្តាល* ហើយលោកក៏ទទួលបានពានរង្វាន់ រ៉ាម៉ុន ម៉ាកសេសេ(Ramon Magsaysay Award) ក្នុងភាពជាអ្នកដឹកនាំសហគមន៍នៅក្នុងឆ្នាំ ២០០៥។

ភរិយារបស់លោកគឺអ្នកស្រី ង៉ំ ស៊ូ ម៉េង (Ng ShuMeng)បានឃើញលោកសម្បត្តិ សំភូន ជាលើកចុងក្រោយ ខណៈដែលពួកគេបានបើករថយន្តដោយឡែកពីគ្នា ចេញពីការិយាល័យរបស់លោកនៅម៉ោងប្រហែល ៥:០០ល្ងាច នាថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១២។ លោកសម្បត្តិ សំភូន មិនបានត្រឡប់មកគេហដ្ឋានវិញដូចសព្វដងនោះទេ ហើយនៅព្រឹកថ្ងៃទី១៦ ខែធ្នូ អ្នកស្រី ង៉ំ ស៊ូ ម៉េង បានរាយការណ៍ពីការបាត់ខ្លួនលោកសម្បត្តិ សំភូន ទៅកាន់អាជ្ញាធរ។ កាមេរ៉ាសន្តិសុខ (ផ្ទាល់ខ្លួន)ដែលក្រុមគ្រួសាររបស់លោកទទួលបាននៅថ្ងៃបន្ទាប់ពីមានការបាត់ខ្លួន បង្ហាញរូបលោកសម្បត្តិ សំភូន ត្រូវបាននគរបាលចរាចរណ៍ឃាត់រថយន្តនៅតាមដងវិថី ថាដាវ (Thadeua)នៅម៉ោងជាង៦:០០ល្ងាចនៅក្នុងទីក្រុងវៀងចាន់(Vientiane)។ កាមេរ៉ានោះ បានបង្ហាញរូបលោក សម្បត្តិ សំភូន ចាកចេញពីឡានរបស់លោក ដោយមានអមដំណើរដោយប៉ូលីសឆ្ពោះទៅកាន់ស្ថានីយនគរបាលបន្ទាប់មកបន្តិចលោកត្រូវបានគេដឹកចេញពីស្ថានីយប៉ូលីសតាមរថយន្តពណ៌សធំមួយ។

ស្របពេលជាមួយគ្នានេះ មន្ត្រីសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ (អ.ស.ប) បានសម្តែងនូវក្តីព្រួយបារម្ភថា លោក សម្បត្តិ សំភូន គឺជាជនរងគ្រោះនៃការបាត់ខ្លួនដោយមានការបង្ខំ។ អាជ្ញាធរឡាវបានបដិសេធជាច់អហង្ការក្នុងការពាក់ព័ន្ធណាមួយចំពោះករណីនេះ។ នៅថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១២ អាជ្ញាធររដ្ឋាភិបាលបានចេញសេចក្តីថ្លែងការណ៍មួយដោយនិយាយថា ការស៊ើបអង្កេតរបស់អាជ្ញាធរចំពោះឧបទ្ទវហេតុនេះឈានទៅរកសេចក្តីសន្និដ្ឋានមួយថា លោកសម្បត្តិ សំភូន ទំនងជាត្រូវបានគេចាប់ជំរិត ដោយហេតុផលនៃរឿងបុគ្គលផ្ទាល់ខ្លួន ហើយអាជ្ញាធរពុំអាចធ្វើអត្ថាធិប្បាយបន្ថែមជាងនេះបានទេ។ មានការអះអាងដូចគ្នានេះដដែលកាលពីថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ ដោយអ្នកតំណាងមកពីប្រទេសឡាវគឺលោកយ៉ុង ចាន់ថាឡងស៊ី (Yong Chanthalangsy) ទៅកាន់អង្គការសហប្រជាជាតិ ក្នុងទីក្រុងហ្សឺណែវ។

ការបាត់ខ្លួនដោយបង្ខំ គឺមានចែងនៅក្នុងមាត្រា០២ នៃអនុសញ្ញាអន្តរជាតិ ដើម្បីធ្វើការការពារដល់ជនគ្រប់រូបទាំងអស់បណ្តាលមកពីការបាត់ខ្លួនដោយបង្ខំ ដូចជា "ការចាប់ខ្លួន ការឃុំខ្លួន ការចាប់ពង្រត់ ឬក៏រូបភាពណាមួយនៃការដកហូតសេរីភាពដោយភ្នាក់ងាររដ្ឋ ឬក៏ដោយជនទាំងឡាយ រឺក្រុមនៃជនណាមួយធ្វើសកម្មភាពដោយមានការអនុញ្ញាតិ ការគាំទ្រ ឬមានការយល់ព្រមពីរដ្ឋ ដែលមានការបដិសេធចំពោះការដឹងលឺ លើការដកហូតសេរីភាព ឬដោយមានការលាក់បំបាំង នូវទីសំចតរបស់ជនដែលបាត់ខ្លួននោះ ដែលជាកន្លែងដែលជនណាម្នាក់ស្ថិតនៅក្រៅការការពារដោយច្បាប់"។ រដ្ឋាភិបាលឡាវ គឺជាហត្ថលេខីនៃអនុសញ្ញានេះ ហើយបច្ចុប្បន្នកំពុងតែត្រៀមខ្លួនផ្តល់សច្ចាប័ន។

ករណីនេះ ក៏មានសារៈសំខាន់ផងដែរដោយសារតែនាពេលថ្មីៗនេះ មានការចុះហត្ថលេខាព្រមព្រៀងលើសេចក្តីប្រកាសសិទ្ធិមនុស្សនៃសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍(ស.ស.ស.ប.អ) កាលពីខែធ្នូ ឆ្នាំ២០១២ ដោយប្រទេសជាសមាជិកទាំង១០ ក្នុងនោះក៏មានប្រទេសឡាវផងដែរ។ ថ្វីបើមានភាពចន្លោះប្រហោងជាច្រើននៅក្នុងសេចក្តីប្រកាសនេះក្តី បើធៀបនិងសេចក្តីថ្លែងការជាសាកលស្តីពីសិទ្ធិមនុស្ស និងយន្តការសិទ្ធិមនុស្សអន្តរជាតិដ៏ទៃទៀត ស.ស.ស.ប.អ បានផ្តល់នូវកិច្ចការពារ ការលើកកម្ពស់ផ្នែកសិទ្ធិមនុស្សនៅទូទាំងប្រទេសក្នុងតំបន់។ ករណីនេះ នាំឲ្យមានការប៉ះពាល់បន្ថែមទៀតចំពោះកិត្យានុភាពលើ ស.ស.ស.ប.អ ហើយនឹងបង្ហាញឲ្យឃើញពីចន្លោះប្រហោងលើសេចក្តីប្រកាសនេះ។

លោកសម្បត្តិ សំភូន គិតមកដល់ពេលនេះបានបាត់ខ្លួនរយៈពេលមួយខែ ហើយយើងក៏មានក្តីព្រួយបារម្ភជាខ្លាំងចំពោះសុខមាលភាពរបស់គាត់ផងដែរ។ ក្តីបារម្ភនេះកើតឡើងព្រមជាមួយនឹងជំនឿទូទៅថា លោកសម្បត្តិ សំភូន ត្រូវបានគេកំណត់ជាមុខសញ្ញា ដោយឃើញពីភាពរីកចម្រើននៃការងារសហគមន៍របស់លោក ហើយលោកបាននឹងកំពុងយកជាឧទាហរណ៍ដោយអាជ្ញាធរប្រទេសឡាវ ដែលប៉ុនប៉ងការពារមិនឲ្យមានការកើនឡើងនៃក្រុមសង្គមស៊ីវិលនៅក្នុងប្រទេស។

ដោយហេតុដូច្នេះ ម.ស.ម.ក សូមអំពាវនាវឲ្យស្ថានទូតឯកឧត្តម ជាពិសេសលោកឯកអគ្គរដ្ឋទូតមេត្តាបញ្ចេញឲ្យអស់ពីសមត្ថភាពនូវឥទ្ធិពលរបស់ខ្លួន ដើម្បីជម្រុញឲ្យអាជ្ញាធរឡាវបើកការស៊ើបអង្កេតជាបន្ទាន់មួយ

ប្រកបដោយភាពហ្មត់ចត់ មិនលម្អៀង និងអាចជឿទុកចិត្តបានក្នុងករណីបាត់ខ្លួនលោកសម្បត្តិ សំភូន នេះនិង ដោយធានាថា យុត្តិធម៌គឺត្រូវបានប្រគល់ជូនដល់សកម្មជនសិទ្ធិមនុស្សរូបនេះនិងក្រុមគ្រួសាររបស់គាត់។

សូមឯកឧត្តមមេត្តាទទួលនូវគោរៈដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ។

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៣

ប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា

អ៊ូ ទីរៈ